ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ **គាំងនាមប្រជារាស្ត្រខ្មែរ**

លេខ : ៦១ **តុលាការកំពូល**

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤

សាលដីកា

លេខ : ២០

ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣០ ខែ មីនា ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក ម៉ុង មុន្នីចរិយា ចៅក្រម

៥- លោក យស់ សូខឿន ចៅក្រម-របាយការណ៍

ក្រឡាបញ្ជី

លោក សុខ ប៊ុនសង

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៦០"ជ" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៦១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ចំពោះ*** : ក្លែងបន្លំលិខិតស្នាមឯកជន ប្រព្រឹត្តនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៨ តាមមាត្រា៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះសូរ្យ ចន្ទ (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះសូរ្យ សាម៉ា "ស" ម្តាយឈ្មោះគិម សា "រ" ប្តីឈ្មោះឆោម ហាក់ មានកូន០៥នាក់ ។

-មេធាវី លោក ឌី បូរីម៉ា

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ ស៊ុនលី( ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

-មេធាវី : លោក អ៊ិន ហ៊ីង

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះឈ ស៊ុនលី បានប្តឹងពីឈ្មោះសូរ្យ ចន្ទ ភេទស្រី និង បក្សពួកថា : បានធ្វើឯកសារក្លែងបន្លំរំលោភយកដីខ្លួន ដែលតុលាការបានចេញសាលក្រមសំរេចឱ្យខ្លួនជាស្ថាពរហើយ ។ ខ្លួនសូមឱ្យចោទប្រកាន់ឈ្មោះសូរ្យ ចន្ទ និង បក្ខពួកពីបទក្លែងលិខិតឯកជន និង ទាមទារជំងឺចិត្ត៧.០០០$ ពីសូរ្យ ចន្ទ និង បក្ខពួក ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តបន្ទាយមានជ័យ ថា : លើកលែងចោទប្រកាន់លើឈ្មោះសូរ្យ ចន្ទ ភេទស្រី អាយុ៤២ឆ្នាំ ពីបទក្លែងលិខិតឯកជន ។

-បានឃើញដីកាលើកលែងចោទប្រកាន់លេខ០៤ ដ.ល.ក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតរបស់តុលាការខេត្តបន្ទាយមានជ័យ ដែលបានសំរេច :

-លើកលែងចោទប្រកាន់លើឈ្មោះសូរ្យ ចន្ទ ភេទស្រី អាយុ៤២ឆ្នាំ ពីបទក្លែងបន្លំលិខិតឯកជនប្រព្រឹត្តនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៧ ខែធ្នូឆ្នាំ១៩៩៨ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះសូរ្យ ចន្ទ ប្តឹងមិនសុខចិត្តពីដីកាលើកលែងចោទប្រកាន់លេខ០៤ដ.ល.ក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតរបស់តុលាការខេត្តបន្ទាយមានជ័យ ត្រង់ចំណុចលើកលែងចោទប្រកាន់ឈ្មោះសូរ្យ ចន្ទ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : តម្កល់ដីកាលើកលែងចោទប្រកាន់លេខ០៤ ដ.ល.ក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០២ ទុកជាបានការដដែល ។

-បានសាលដីកាព្រហ្មទណ្ឌលេខ៦០"ដ" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះឈ ស៊ុនលី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើករចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីការលើកលែងចោទប្រកាន់លេខ០៤ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តមានជ័យ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារ និង កំបាំងមុខជនជាប់ចោទ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះឈ ស៊ុនលី ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៦០"ដ" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះឈ ស៊ុនលី (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះសួប្រ ចន្ទ និង អោម ហាក់ ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : ក្នុងរឿងនេះ សូមតុលាការ ពិចារណាលើលិខិតលក់-ទិញ របស់ជនជាប់ចោទដែលថា ខ្លួនទិញពីស្រុក ចុះហេតុអ្វីនៅពេលនេះ ស្រាប់តែអភិបាលរងខេត្តបានបញ្ជាក់ថា ក្នុងឆ្នាំ១៩៩៣ ទ្រព្យសម្បត្តិរដ្ឋគ្មានចំនុចដីទំនាស់នេះទេ ហើយក៏ពុំមែនជាដីបំរុងរបស់រដ្ឋដែរ ។ លិខិតកាន់កាប់ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៨ គឺខុសគ្នារយៈពេល៦ខែ ដូច្នេះជនជាប់ចោទពិតជាបានប្រឌិតភស្តុតាងក្លែង ដែលមិនពិតធ្វើឱ្យតុលាការជឿ ទើបតុលាការគ្រប់ថ្នាក់ជឿរហូត ដែលបានធ្វើឱ្យជនជាប់ចោទឈ្នះក្តីក្នុងរឿងរដ្ឋប្បវេណី ។ បើផ្អែកតាមមាត្រា ៥៦ នៃច្បាប់អ៊ុនតាក់ ឃើញថាជនជាប់ចោទបានជូនភស្តុតាងមិនពិតឱ្យតុលាការជឿជាក់ វាត្រូវតែជាប់ពីបទធ្វើសក្ខីភាពក្លែង ក្លាយ ។

ដូច្នេះសូមតុលាការបញ្ជូនសំណុំរឿងនេះទៅតុលាការខេត្តបន្ទាយមានជ័យឱ្យចោទពីបទ ធ្វើសក្ខីភាពក្លែងក្លាយ និង សូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះឈ ស៊ុនលី ( ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្ញុំមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទេ ដោយពុំមានយុត្តិធម៌ឡើយចំពោះខ្ញុំ ព្រោះដីទំនាស់នោះជាដីរបស់ខ្ញុំ ដែលឈ្មោះហេង ណារិន បានប្រគល់ឱ្យខ្ញុំតាមរយៈខ្ចីលុយខ្ញុំ១០ម៉ឺនបាត ហើយមិនសងលុយវិញ ។ ស្រាប់តែឈ្មោះសួប្រ ចន្ទ ថាដីនោះជាដីរបស់ខ្លួន ដែលបានទិញស្រុកទៅវិញ :

+លិខិតទិញ-លក់ រវាងស្រុក និង សួប្រ ចន្ទ គឺគ្មានសាក្សី

+ពេល ហេង ណារិន បានយកដីទំនាស់នោះមកបញ្ចាំឱ្យខ្ញុំ ដីនោះមានបោះបង្គោលរួចហើយ មានទំហំ១៨ម×៥០ម ដូច្នេះសូមតុលាការបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទ ឈ្មោះសួប្រ ចន្ទ ( ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : +នាងខ្ញុំមិនបានក្លែងលិខិតអ្វីទេ ព្រោះតុលាការកំពូលបានសំរេចដីនេះឱ្យខ្ញុំហើយ

+ពេលគេប្រគល់លិខិតទិញ-លក់ ទើបនាងខ្ញុំផ្តិតមេដៃប្រគល់ប្រាក់ឱ្យគេវិញ ខ្ញុំមិនមែនផ្តិតមេដៃធ្វើលិខិតក្លែងទេ .

+ពេលខ្ញុំទិញពីស្រុក ស្រុកថាដីនេះជាដីបំរុងរបស់ស្រុក

+លិខិតស្នាមអ្វីៗ ស្រុកជាអ្នកចាត់ចែងទាំងអស់ ខ្ញុំដឹងតែផ្តិតមេដៃប្រគល់លុយឱ្យស្រុកប៉ុណ្ណោះ ព្រោះស្រុកត្រូវការលុយ .

+ប៉ុន្តែដំបូងដីនេះ ហេង ណារិន យកមកបញ្ចាំខ្ញុំ ក្រោយពីមានការសះជាងនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ រវាងខ្ញុំ និង ហេង ណារិន ព្រោះខ្ចីលុយខ្ញុំ

+ពេល ហេង ណារិន វត់បាត់ នាងខ្ញុំសុំកាន់កាប់ស្រាប់តែស្រុកថា មិនមែនដីរបស់ ហេង ណារិន ទេ បើចង់បានត្រូវទិញពីអាជ្ញាធរស្រុក នាងខ្ញុំក៏ព្រមទិញទៀត ដូច្នេះរឿងថាក្លែងនោះ មិនទាក់ទងទៅនឹងនាងខ្ញុំទេ ព្រោះអាជ្ញាធរស្រុកដែលមានសមត្ថកិច្ចច្បាស់លាស់បញ្ជាក់ហើយបញ្ជាក់ទៀតថា ដីទំនាស់នោះជាដីបំរុងរបស់រដ្ឋ ហេតុនេះរឿងធ្វើលិខិតទិញ-លក់នោះ គ្មានពាក់ព័ន្ធនឹងនាងខ្ញុំទេ ។

-ក្រុមប្រឹក្សាជំនុំជំរះសួរឈ្មោះសួរ្យ ចន្ទ ថា ហេតុអ្វីបានជាអ្នកស្រីដាក់ពាក្យសុំកាន់កាប់ដីនោះមុនទិញពីស្រុកទៅវិញ ?

ឆ្លើយ : បានសុំកាន់កាប់ដីនោះមុខទិញពីស្រុក ព្រោះមុនដំបូងគឺខ្ញុំគ្រាន់តែដាក់ពាក្យសុំកាន់កាប់ទេ ក្រោយពីមានដីកាសះជាហើយ ពេលនោះឈ្មោះហេង ណារិន ក៏វត់បាត់ទៀត នាងខ្ញុំក៏សុំកាន់កាប់តែម្តង ស្រាប់តែអភិបាលស្រុកថា ដីនេះជាដីបំរុងរបស់រដ្ឋ បើនរណាចង់បានត្រូវតែទិញពីស្រុក ពេលនោះនាងខ្ញុំក៏សុខចិត្តទិញទៀត ដោយលោកញៀក ចំរើន ជាអភិបាលស្រុកជាអ្នកសរសេរកិច្ចសន្យាទិញ-លក់នោះ ទើបកិច្ចសន្យាទិញ-លក់ ក្រោយលិខិតកាន់កាប់ ព្រោះពេលនាងខ្ញុំទិញពួកស្រុកពុំទាន់យល់ព្រមភ្លាម១នោះទេ គឺរយៈពេលយូរទើបពួកស្រុកស្រុះស្រួលព្រមលក់ឱ្យ ហើយដីទិញពីស្រុកគឺចំណុចA ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកអ៊ិន ហ៊ីង ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឈ ស៊ុនលី (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា :

+ប្រវត្តិដីនោះ គឺកូនក្តីខ្ញុំបានទទួលការបញ្ចាំពីឈ្មោះហេង ណារិន ហើយមានអភិបាលស្រុកក៏ចូលរួមទទួលស្គាល់ថា ដីនោះជាដីរបស់ហេង ណារិន ពិតប្រាកដ .

+ដីទំនាស់នេះមិនមែនជាដីបំរុងទេ

+ទីតាំងដីទំនាស់ និង ដីរបស់ស្រុកគឺស្ថិតនៅឆ្ងាយពីគ្នាចំងាយពីគ្នាប្រហែល១៤០០ម ដែលមានមេឃុំបញ្ជាក់ច្បាស់ .

+ពិសេសទៅទៀត មានការបញ្ជាក់របស់ក្រសួងហិរញ្ញវត្ថុ ,អភិបាលរងខេត្ត ថាដីទំនាស់នេះមិនមានក្នុងសារពើភ័ណ្ឌរបស់រដ្ឋទេ .

+ចំណុចមិនប្រក្រតី គឺលិខិតកាន់កាប់ធ្វើមុនលិខិតទិញ-លក់.

+គាត់មានចេតនាបន្លំចង់យកដីនោះ ព្រោះថាបើតាមលិខិតសះជានៅថ្ងៃទី០៦-១១-១៩៩៨ គឺទើបគេប្រគល់ដីនោះឱ្យគាត់ តែបែរជាគាត់បានដាក់ពាក្យកាន់កាប់តាំងពី២៤-៦-១៩៩៨ ទៅវិញ ដូច្នេះតាំងពីស៊ុវិយាជី,ចៅហ្វាយស្រុក និងឈ្មោះសួរ្យ ចន្ទ បានឃុំឃិតគ្នាធ្វើជាសក្ខីភាពមិនពិតជូនមកតុលាការទាំងបីឱ្យជឿ ពិសេសទៅទៀតលិខិតនោះបានយកលេខរបស់គេមកដាក់ថែមទៀតផង ហេតុនេះសូមតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល និង បញ្ជូនសំណុំរឿងឱ្យតុលាការខេត្តចោទពីបទធ្វើសក្ខីភាពក្លែងក្លាយ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឌី ប៊ូរីម៉ា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះសួរ្យ ចន្ទ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា :

+ដីនោះមានចំណុច A ,B ,C ដីចំនុចA ជាដីទំនាស់

+ក្រោយពីបានដឹងថា ដីនោះជាដីរបស់ស្រុកហើយ អាជ្ញាធរស្រុកត្រូវការលុយ ទើបកូនក្តីខ្ញុំដាក់ពាក្យសុំកាន់កាប់ និង សុំទិញតែម្តង .

+ប៉ុន្តែការទិញដីពីស្រុកមិនមែនថា ទិញភ្លាមបានដីនោះមកភ្លាមទេ គឺអាជ្ញាធរស្រុកគឺចាត់ចែងតាមនីតិវិធីតាំងពីភូមិ-ឃុំ រហូតដល់ស្រុក ទើបសំរេច គឺរយៈពេលជាច្រើនខែ គិតពីថ្ងៃកូនខ្ញុំចង់ទិញ លុះថ្ងៃខែឆ្នាំដែលសំរេចនោះ គឺថ្ងៃ ខែ ឆ្នាំ ប្រគល់ដី ប្រគល់លុយ ដូច្នេះមិនមានការដាក់សុំកាន់កាប់មុន ទើបទិញជាក្រោយនោះទេ .

+រាល់លិខិតស្នាម គឺលោកសៀង មុត បានបំពេញឱ្យកូនក្តីខ្ញុំទាំងអស់ ហើយលិខិតលក់-ទិញ ក៏លោកញ៉េក ចំរើន ជាអ្នកសរសេរឱ្យគាត់ទៀត ដូច្នេះកូនក្តីខ្ញុំមិនដឹងពីរឿងក្លែងនោះទេ ព្រោះអាជ្ញាធរស្រុកបានបញ្ជាក់ថា ដីចំណុចA ត្រូវតែទិញពីស្រុក កូនក្តីខ្ញុំក៏បានដាក់ពាក្យសុំនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៨ តែស្រុកស្រុះស្រួលគ្នាដល់ទៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៨ .

+តុលាការខេត្តបន្ទាយមានជ័យបានកោះហៅលោកញ៉េក ចំរើន និង លោកសៀង មុត មកសួរហើយមកសួរទៀត ដោយបញ្ជាក់ច្បាស់ថា ជាដីបំរុងរបស់រដ្ឋ ហើយពួកគាត់ជាអ្នកសរសេររាល់លិខិតស្នាមទាំងអស់ ដូច្នេះហើយទើបតុលាការខេត្តយល់ថា គ្មានបទក្លែងលិខិត ឬ សក្ខីភាពក្លែងអ្វីទេ ។

+តាមច្បាប់កិច្ចសន្យា គឺគូភាគីជាអ្នកប្តឹង ចំណែកលោកឈយ ស៊ុនលី មិនមែនជាគូភាគីកិច្ចសន្យាទេ ។

+ពិសេសទៅទៀតដីត្រង់ចំណុចនេះ ត្រូវបានចៅក្រម៥រូបនៅតុលាការកំពូលនេះបានសំរេចនៅថ្ងៃទី២៩-៨-២០០២ គឺបានប្រគល់ដីនោះឱ្យកូនក្តីខ្ញុំចូលស្តាពរជាង២ឆ្នាំមកហើយ ហើយពេលនោះក៏មានចៅក្រមពីររូបមួកចូលរួមជំនុំជំរះនាពេលនេះដែរ ។

+ក្រោយពីបានសូត្រតាមការយល់ឃើញក្នុងសាលដីការដ្ឋប្បវេណីរបស់តុលាការកំពូល និង ផ្អែកតាមមាត្រា៤៩ នៃច្បាប់អ៊ុនតាក់ គឺកូនក្តីខ្ញុំគ្មានប្រព្រឹត្តបទល្មើសអ្វីទេ ។

+ចំពោះរឿងស្រុកប្រឌិត ឬ មិនប្រឌិត គឺជារឿងរបស់ស្រុកទេ កូនក្តីខ្ញុំជាប្រជាពលរដ្ឋក្នុងមូលដ្ឋានស្រុក គឺមិនដឹងអ្វីទាំងអស់ ដូច្នេះបើស្រុកជាអ្នកប្រឌិតនោះ ត្រូវឈ្មោះឈ ស៊ុនលី ទៅប្តឹងពីស្រុកទៅ គ្មានអ្វីពាក់ព័ន្ធជាមួយកូនក្តីខ្ញុំទេ គឺកូនក្តីខ្ញុំមិនដឹងអ្វីទាំងអស់ ។ ដូច្នេះផ្អែកទៅសាលដីការដ្ឋប្បវេណីដែលបានចូលស្តាពរនៅតុលាការកំពូលនេះ អស់រយៈពេល២ឆ្នាំ ៧ខែមកហើយ សូមតុលាការកំពូលសំរេចដោយគតិបណ្ឌិត ឱ្យកូនក្តីខ្ញុំផង ដោយតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលសវនាការ ថា : នេះមិនមានជាភស្តុតាង លិខិតក្លែងទេ តែសូមពិចារណាលើសក្ខីភាពក្លែងដែលប្រព្រឹត្តក្នុងនីតិវិធីក្លែង ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពារមេធាវីរបស់ជនជាប់ចោទ និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះឈ ស៊ុនលី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលើកលែងចោទប្រកាន់លើឈ្មោះសូរ្យ ចន្ទ ពីបទក្លែងបន្លំលិខិតស្នាម ដោយតម្កល់ដីកាលើកលែងចោទប្រកាន់លេខ០៤ ចុះថ្ងៃទី៤ ខែកុម្ភៈឆ្នាំ២០០២របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តបន្ទាយមានជ័យ ដោយសំអាងថា ដីត្រង់ចំណុចទំនាស់ជាដីរបស់សាលាស្រុកអូរជ្រៅ ឈ្មោះសូរ្យ ចន្ទ បានទិញពីស្រុកកាលថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៨ ហើយថា តុលាការកំពូលបានសំរេចជាស្ថាពរប្រគល់ដីនេះឱ្យជនជាប់ចោទហើយ នោះពុំទាន់មានសំអាងហេតុគ្រប់គ្រាន់ទេ ពីព្រោះក្នុងការសំរេចសេចក្តីក្នុងរឿងរដ្ឋប្បវេណី តុលាការកំពូលបានជឿជាក់ថា ដីនេះជាដីរបស់អាជ្ញាធរស្រុកដែលលក់ឱ្យជនជាប់ចោទ ប៉ុន្តែក្នុងរឿងក្តីពេលនេះ ក្រសួងហិរញ្ញវត្ថុ ,អភិបាលរងខេត្តបន្ទាយមានជ័យរបាយការណ៍ស្តីពីអាជកំបាំងដីធ្លីនៅប៉ោយប៉ែត ,លិខិតបញ្ជាក់ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ របស់លោកវណ្ណ សុជាត ,លិខិតបញ្ជាក់ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់មេឃុំប៉ោយប៉ែត ,លិខិតបំភ្លឺ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ របស់មេភូមិប៉ោយប៉ែត ដែលត្រូវបានផ្តល់ជូនតុលាការក្នុងរឿងព្រហ្មទណ្ឌក្រោយសាលដីការដ្ឋប្បវេណីស្ថាពររបស់តុលាការកំពូល បញ្ជាក់ឱ្យឃើញថា ដីទំនាស់ដែលលោកញ៉ែក-ចំរើន លក់ឱ្យជនជាប់ចោទពុំមែនជាដីស្រុកទេ ។

-យល់ឃើញថា រឿងក្តីនេះមានពាក់ព័ន្ធដល់ជនដទៃផ្សេងទៀត ដែលបានរៀបចំឯកសារសុទ្ធតែធ្វើឱ្យតុលាការជឿតាម ពុំទាន់ត្រូវបានចោទប្រកាន់ និង ស៊ើបសួរដើម្បីរកឱ្យឃើញអំពីការទទួលខុសត្រូវរបស់ជនម្នាក់ៗ ក្នុងបទធ្វើសក្ខីកម្មក្លែងក្លាយ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦០"ជ" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

## ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទ**

១-ទទួលបណ្តឹងសាទុក្ខលេខ១០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះឈ ស៊ុនលី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៦០"ជ" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ពេញទាំងមូលដោយឥតបង្អិល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៦១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅតុលាការខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការបន្តទៀតតាមច្បាប់ ។

៤-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។